ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៥៩០ ប.សណ៣

ថ្ងៃសុក្រ ១៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០២១

**ជម្រាបជូន**

- **ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ**
- **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
- **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល**
- **ឯកឧត្តម អគ្គាធិការ នៃអគ្គាធិការដ្ឋាន**
- **ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ១ អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ**
- **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍**
- **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**
- **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ**
- **ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា**
- **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង**
- **ឯកឧត្តម ប្រធានក្រុមប្រឹក្សានីតិកម្ម**
- **ឯកឧត្តម ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**
- **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ**
- **លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
- **ឯកឧត្តម ឧត្តមសេនីយ៍ឯក ប្រធានលេខាធិការដ្ឋាន គ.ប.ជ.ក**
- **ឯកឧត្តម ឧត្តមសេនីយ៍ទោ ប្រធានលេខាធិការដ្ឋានស្ថិតិ គ.ជ.ប.ន**

**<u>កម្មវត្ថុ</u>** : ស្តីពីការអនុវត្តវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ "សហគមន៍ ២០ កុម្ភៈ" ។

**<u>យោង</u>** : ប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** ជ្រាបថា ក្នុងគោលបំណងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ "សហគមន៍ ២០ កុម្ភៈ" ក្រសួងមហាផ្ទៃ ស្នើ **ឯកឧត្តម លោកជំទាវ** អនុវត្តឲ្យបានខ្ជាប់ខ្ជួនម៉ឺងម៉ាត់នូវវិធានការរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ព្រមទាំងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដោយធ្វើការណែនាំដល់មន្ត្រីក្រោមឱវាទអនុវត្តជាប់ជាប្រចាំនូវវិធានការដូចខាងក្រោម៖

- ពង្រឹងការត្រួតពិនិត្យមន្ត្រីរាជការចេញ-ចូលក្នុងពេលបំពេញភារកិច្ចតាមច្រកទ្វារនីមួយៗដោយធ្វើការវាស់កម្តៅ និងប្រើទឹកអាល់កុលសម្រាប់លាងដៃ មុនអនុញ្ញាតឱ្យចូលបម្រើការងារ
- ធ្វើការផ្សព្វផ្សាយដល់មន្ត្រីក្រោមឱវាទស្តីពីការបង្ការ ទប់ស្កាត់ការរាតត្បាត នៃជំងឺកូវីដ១៩ និងឱ្យប្រកាន់យកនូវវិធានការអនាម័យជាប្រចាំក្នុងការិយាល័យ និងលាងដៃជាមួយទឹកអាល់កុល ឬសាប៊ូឱ្យបានញឹកញាប់ចៀសវាងការយកដៃមកប៉ះពាល់លើផ្ទៃមុខ
- ត្រូវផ្អាកជាបណ្តោះអាសន្ននូវការជួបជុំ ការបណ្តុះបណ្តាល ការប្រារព្ធពិធី ការសំណេះសំណាលនានាដែលមានលក្ខណៈទ្រង់ទ្រាយធំ និងមានមនុស្សចូលរួមកុះករ
- ត្រូវតាមដាន ត្រួតពិនិត្យសុខភាពរបស់ខ្លួនជាប្រចាំ សម្រាប់មន្ត្រីរាជការដែលមានអាការក្តៅខ្លួន ក្អក ផ្តាសាយ ឬមានការសង្ស័យណាមួយពាក់ព័ន្ធនឹងជំងឺកូវីដ១៩ ពុំចាំបាច់មកបំពេញការងារនោះទេនិងត្រូវរាយការណ៍ទៅអង្គភាពរបស់ខ្លួន ហើយត្រូវប្រញាប់ទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតបំផុត ឬទាក់ទងទៅភ្នាក់ងារសុខាភិបាលតាមរយៈលេខទូរស័ព្ទ ១១៥
- ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការ ៣ការពារ (៣ក់ម៉ាស់, លាងដៃ, គម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល ចាប់ពី១,៥០ម៉ែត្រ ឡើងទៅឱ្យបានគ្រប់គ្នា នៅគ្រប់ទីកន្លែង និងអនុវត្តឱ្យបានគ្រប់គ្នា) និង៣កុំ (កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល និងប្រើម៉ាស៊ីនត្រជាក់ច្រើនពេក រកកន្លែងមានខ្យល់ចេញចូល, កុំទៅកន្លែងមនុស្សច្រើនកុះករ, កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា កុំឱបថើបគ្នាជាដើម)។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** ជ្រាប និងផ្សព្វផ្សាយដល់មន្ត្រីក្រោមឱវាទចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការប្រចាំការ

**សក់ សេដ្ឋា**

<u>ចម្លងជូន :</u>

- *ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ*
- *ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*
- *ឯកសារ-កាលប្បវត្តិ*